**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**អគ្គនាយកដ្ឋានកៅស៊ូ**

លេខ: ៧៣១ អក.កស

ថ្ងៃច័ន្ទ ១៣កើត ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ២០១៩

**សូមគោរពជូន**

**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**កម្មវត្ថុ** ៖ របាយការណ៍ស្តីពីស្ថានភាពការងារអគ្គនាយកដ្ឋានកៅស៊ូប្រចាំខែកុម្ភៈ ឆ្នាំ២០១៩ និងទិសដៅអនុវត្តបន្ត។

**ជូនភ្ជាប់** ៖ -តារាងស្ថានភាពផលិតកម្មកៅស៊ូប្រចាំខែកុម្ភៈ ឆ្នាំ២០១៩

-តារាងស្ថានភាពធុរកិច្ចផលិតផលកៅស៊ូស្ងួតប្រចាំខែកុម្ភៈ ឆ្នាំ២០១៩ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងជូនភ្ជាប់ខាងលើ ខ្ញុំបាទសូមជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលជ្រាបអំពីលទ្ធផលការងារសម្រេចបានរបស់អគ្គនាយកដ្ឋានកៅស៊ូប្រចាំខែកុម្ភៈ ឆ្នាំ២០១៩ និងទិសដៅអនុវត្តបន្តដោយសង្ខេបដូចខាងក្រោម៖

១-ផ្ទៃដីកៅស៊ូសរុបមានចំនួន ៤៣៦ ៥៦០ ហិកតា ក្នុងនោះ៖ ផ្ទៃដីចៀរជ័រមានចំនួន ២០១ ៧៦៩ ហិកតា ស្មើនឹង ៤៦% និងផ្ទៃដីថែទាំមានចំនួន ២៣៤ ៧៩១ ហិកតា ស្មើនឹង៥៤%។

២-បរិមាណផលិតផលសម្រេចបានក្នុងខែកុម្ភៈ ឆ្នាំ២០១៩ មានចំនួន ១១ ៩២៨ តោន បានថយចុះចំនួន ១៣ ០៥៦ តោនស្មើនឹង៥២%ធៀបនិងខែមុន នឹងបានកើនឡើងចំនួន ២ ៧៤៨តោន ៣០% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។

៣-បរិមាណបញ្ចេញលក់សម្រេចបានក្នុងខែកុម្ភៈ ឆ្នាំ២០១៩ មានចំនួន ១៣ ០៤៤ តោន បានថយចុះចំនួន ១០ ៤០៧ តោន ស្មើនឹង៤៤%ធៀបនិងខែមុន នឹងបានកើនឡើងចំនួន ៣ ២១៧តោនស្មើនឹង ៣៣%ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។

៤-តម្លៃលក់ជ័រកៅស៊ូមធ្យមសម្រេចបានក្នុងខែកុម្ភៈឆ្នាំ២០១៩ មានចំនួន ១ ២៩៩ដុល្លារ/តោន បានកើនឡើងចំនួន ៧៣ដុល្លារ/តោន ស្មើនឹង(៥.៩៦%)ធៀបនិងខែមុន ប៉ុន្តែបានថយចុះ២០២ដុល្លារ/តោន ស្មើនឹង១៣% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។

៥-ទិសដៅបន្ត៖

- ប្រជុំពិនិត្យនិងកែសម្រួលសេចក្តីព្រាងច្បាប់ស្តីពីកៅស៊ូ
- បន្តចុះអនុវត្តសកម្មភាពគម្រោងតាមកម្មវិធីឲ្យបានសម្រេចតាមផែនការដែលបានគ្រោងទុក
- ចុះត្រួតពិនិត្យនិងវាយតម្លៃបច្ចេកទេសដំណាំកៅស៊ូរបស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច និងជំរុញការប្រមូលចំណូលចូលថវិការដ្ឋតាមការគ្រោងទុក
- ផ្សព្វផ្សាយតម្លៃកៅស៊ូតាមវិទ្យុ លើទំព័រហ្វេសប៊ុក និងព្រឹត្តិបត្ររបស់អគ្គនាយកដ្ឋានកៅស៊ូ។

អាស្រ័យដូចបានជម្រាបជូនខាងលើ ខ្ញុំបាទសូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលជ្រាបជារបាយការណ៍ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ជ្រាលជ្រៅអំពីខ្ញុំបាទ។

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**

**អគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ**

**ប៉ុល សុផា**

**ចម្លងជូន៖**

- ឯកឧត្តមរដ្ឋលេខាធិការទទួលបន្ទុក
- ឯកឧត្តមអនុរដ្ឋលេខាធិការទទួលបន្ទុក

"ដើម្បីជូនជ្រាប"

- នាយកដ្ឋានកិច្ចការរដ្ឋបាល កសក.
- នាយកដ្ឋានផែនការ និងស្ថិតិ កសក.
- នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃ អនក.
- គ្រប់ចម្ការកៅស៊ូកសិ-ឧស្សាហកម្ម

"ដើម្បីជ្រាប"

- ឯកសារ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**អគ្គនាយកដ្ឋានកៅស៊ូ**

# របាយការណ៍
## ស្ដីពី
## ស្ថានភាពការងាររបស់អគ្គនាយកដ្ឋានកៅស៊ូ ប្រចាំខែកុម្ភៈ ឆ្នាំ២០១៩ និងទិសដៅអនុវត្តបន្ត

### ១.សេចក្ដីផ្ដើម

ក្នុងឆ្នាំ២០១៩ នេះអគ្គនាយកដ្ឋានកៅស៊ូ បានអនុវត្តការងារចម្បងៗ ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ទាំងការងារចរន្ត ការងារអនុវត្តគម្រោងតាមកម្មវិធី ការងារដាំដុះ ថែទាំកូនកៅស៊ូថ្មី ការងារអាជីវកម្ម ផលិតកម្ម និងធុរកិច្ច ទាំងកៅស៊ូគ្រួសារនិងកៅស៊ូកសិ-ឧស្សាហកម្ម និងការងារផ្សេងៗទៀតបានដំណើរការជាធម្មតា។ ជាលទ្ធផលការងារសំខាន់ៗ ដែលអគ្គនាយកដ្ឋានកៅស៊ូសម្រេចបានប្រចាំខែកុម្ភៈ ឆ្នាំ២០១៩ មានខ្លឹមសារលម្អិតជូនដូចខាងក្រោម៖

### ២.លទ្ធផលការងារសម្រេចបាន

#### ២.១ ការងារអាជីវកម្ម ផលិតកម្ម និងធុរកិច្ចកៅស៊ូ

##### ២.១.១ ផ្ទៃដីកៅស៊ូ

ផ្ទៃដីកៅស៊ូសរុបមានចំនួន ៤៣៦ ៥៦០ ហិកតា ដែលក្នុងនោះ៖ ផ្ទៃដីចៀរជ័រមានចំនួន ២០១ ៧៦៩ ហិកតា ស្មើនឹង ៤៦% និងផ្ទៃដីថែទាំមានចំនួន ២៣៤ ៧៩១ ហិកតា ស្មើនឹង ៥៤%។

##### ២.១.២ ផលិតកម្ម

ផលិតផលជ័រកៅស៊ូសម្រេចបានក្នុងខែកុម្ភៈ ឆ្នាំ២០១៩ មានចំនួន ១១ ៩២៨តោន បានថយចុះចំនួន ១៣ ០៥៦ តោន ស្មើនឹង ៥២%ធៀបនិងខែមុន នឹងបានកើនឡើងចំនួន ២ ៧៤៨តោនស្មើនឹង ៣០% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។

ផលិតផលជ័រកៅស៊ូសរុបគិតមកដល់ខែកុម្ភៈ ឆ្នាំ២០១៩ សម្រេចបានចំនួន ៣៦ ៩១២ តោន បានកើនឡើងចំនួន ៨ ៨២៨តោន ស្មើនឹង ៣១% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។

##### ២.១.៣ ធុរកិច្ចកៅស៊ូ

បរិមាណបញ្ញាញលក់ជ័រកៅស៊ូសម្រេចបានក្នុងខែកុម្ភៈ ឆ្នាំ២០១៩ មានចំនួន ១៣ ០៤៤ តោន បានថយចុះចំនួន ១០ ៤០៧ តោន ស្មើនឹង៤៤%ធៀបនិងខែមុន នឹងបានកើនឡើងចំនួន ៣ ២១៧តោន ស្មើនឹង ៣៣% បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។

បរិមាណបញ្ចេញលក់សរុបគិតមកដល់ត្រឹមខែកុម្ភៈ ឆ្នាំ២០១៩ សម្រេចបានចំនួន ៣៦ ៤៩៥ តោន បានកើនឡើងចំនួន ៧ ៨០១ តោន ស្មើនឹង ២៧% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។

តម្លៃលក់មធ្យមក្នុងខែកុម្ភៈ ឆ្នាំ២០១៩ មានចំនួន ១ ២៩៩ដុល្លារ/តោន បានកើនឡើង ៧៣ដុល្លារ/តោន ស្មើនឹង ៥,៩៦%ធៀបនឹងខែមុន និងបានថយចុះចំនួន ២០២ដុល្លារ/តោន ស្មើនឹង ១៣% បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំមុន។

តម្លៃលក់កៅស៊ូជាមធ្យមគិតក្នុងខែកុម្ភៈ ឆ្នាំ២០១៩ គឺ ១ ២៥២ ដុល្លារ/តោន បានថយចុះចំនួន ២០៦ ដុល្លារ/តោន ស្មើនឹង ១៤% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។

អាស័យដ្ឋាន៖ ផ្លូវជាតិលេខ៦អា ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ កម្ពុជា
Address: National Road No.6A, Phum Bakkheng, Sangkat Prek Leap, Khan Chroy Changva, Phnom Penh
ទូរស័ព្ទលេខ៖ (៨៥៥) ២៣ ៦៧២២ ៥៩០
Phone: (855) 23 6722 590, Email:gdr.maff@gmail.com

## ២.២. ការងារចរន្តនិងការអនុវត្តគម្រោងសកម្មភាពថវិកាតាមកម្មវិធី

### ២.២.១. ការងារចរន្ត

- បានចុះផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តដែលពាក់ពន្ធ័វិស័យកៅស៊ូ នៅក្នុងស្រុកបរកែវ ខេត្តរតនៈគីរី
- បានចុះបើកវគ្គបណ្តុះបណ្តាលជំនាញចៀរជ័រដល់កសិករកៅស៊ូគ្រួសារនៅខេត្តព្រៃវែង
- បានចុះបើកវគ្គពង្រឹងសហគមន៍កសិកម្មកៅស៊ូគ្រួសារ នៅខេត្តកំពង់ធំ
- បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០១៨ និងលើកទិសដៅអនុវត្តការងារឆ្នាំ២១០៩ របស់អគ្គនាយកដ្ឋានកៅស៊ូ
- រៀបចំគម្រោងកម្មវិធីវិនិយោគសាធារណៈ(ក.វ.ស) ៣ឆ្នាំរំកិល ២០២០-២០២២ របស់អគ្គនាយកដ្ឋានកៅស៊ូ
- បានសិក្សាស្រាវជ្រាវប្រមូលទិន្នន័យនិងព័ត៌មានកៅស៊ូ សម្រាប់រៀបចំព្រឹត្តិបត្រប្រចាំខែ និងផ្សព្វផ្សាយតម្លៃកៅស៊ូធម្មជាតិលើទំព័រហ្វេសប៊ុករបស់អគ្គនាយកដ្ឋានកៅស៊ូ
- តាមដានត្រួតពិនិត្យ ស្រាវជ្រាវអំពីតម្លៃកៅស៊ូនៅទីផ្សារក្នុងស្រុក និងអន្តរជាតិ
- បានប្រមូលទិន្នន័យ និងរៀបចំតម្លៃកៅស៊ូធម្មជាតិសម្រាប់ផ្សាយប្រចាំសប្តាហ៍តាមវិទ្យុមណ្ឌលព័ត៌មានស្ត្រីកម្ពុជា(FM103.5)ចំនួន០៤ដង(១សប្តាហ៍១ដង) និងបានផ្សាយបន្តផ្ទាល់ទៅតាមបណ្តាលខេត្តចំនួន៤ ខេត្ត ខេត្តបាត់ដំបង(FM106.3) ខេត្តកំពង់ចាម(FM 99.3) ខេត្តកំពង់ធំ(FM104) ខេត្តសៀមរាប(FM107) រៀងរាល់ថ្ងៃចន្ទ វេលាម៉ោង១០ព្រឹក។

### ២.២.២. ការចំណាយថវិកាតាមគម្រោងកម្មវិធី

ការចំណាយថវិកាក្នុងខែកុម្ភៈ ឆ្នាំ២០១៩ មានចំនួន ១៤៦ ១៣៦ ៣០០ រៀល។ បើគិតមកដល់ខែកុម្ភៈឆ្នាំ២០១៩ ការចំណាយមានចំនួន២២៧ ០១៣ ៩០០

### ២.២.៣. ការប្រមូលចំណូលថវិកា

ការប្រមូលចំណូលថ្លៃឈ្នួលដីអវិនិយោគចម្ការកៅស៊ូរដ្ឋទាំង៧ ចម្ការកៅស៊ូរដ្ឋឡាបានសៀកខេត្តរតនគីរី និងក្រុមហ៊ុននីហាវ៉ណ អាហារ៉ណកៅស៊ូ គិតក្នុងខែកុម្ភៈ ឆ្នាំ២០១៩ មិនទាន់ដល់ការបរិច្ឆេទត្រូវបង់ទេ។

## ៣. ទិសដៅបន្ត

- បន្តរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធកៅស៊ូ
- បន្តចុះផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុទ្ធតាមខេត្តដែលបានគ្រោងទុក
- បន្តរៀបចំកិច្ចបញ្ជិការជួទេយ្យចំណូល - ចំណាយ និងរបាយការណ៍អនុវត្តចំណូល - ចំណាយរបស់អគ្គនាយកដ្ឋានកៅស៊ូ
- រៀបចំគម្រោងផែនការសកម្មភាពថវិកាកម្មវិធីសម្រាប់ឆ្នាំ២០២០
- រៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០១៨ និងលើកទិសដៅការងារឆ្នាំ២១០៩ របស់អគ្គនាយកដ្ឋានកៅស៊ូ
- បន្តចុះវគ្គបណ្តុះបណ្តាលជំនាញចៀរជ័រដល់កសិករកៅស៊ូគ្រួសារ
- បន្តចុះពង្រឹង និងចងក្រងសហគមន៍កសិករកៅស៊ូគ្រួសារ
- បន្តចុះបើកវគ្គផ្សព្វផ្សាយ ដំណាំកៅស៊ូដល់កសិករកៅស៊ូគ្រួសារ

- បន្តចុះពិនិត្យ និងវាយតម្លៃបច្ចេកទេសដំណាំកៅស៊ូរបស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច
- បន្តស្រាវជ្រាវនិងប្រមូលទិន្នន័យកៅស៊ូក្នុងស្រុក និងអន្តរជាតិ
- បន្តចុះពង្រឹង និងចងក្រងសហគមន៍ កសិករកៅស៊ូគ្រួសារសម្រាប់រៀបចំព្រឹត្តិបត្រប្រចាំខែ និង ផ្សព្វផ្សាយតម្លៃកៅស៊ូធម្មជាតិតាមវិទ្យុប្រចាំសប្តាហ៍ និងលើគេហទំព័រហ្វេសប៊ុក របស់អគ្គនាយកដ្ឋានកៅស៊ូ។

ថ្ងៃច័ន្ទ១៣កើតខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩
**ប្រធាននាយកដ្ឋានរដ្ឋបាលនិងនីតិកម្ម**

ឃួន_ផល្លា

**បានឃើញនិងឯកភាព**
**ជ.ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**
**អគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ**
**អគ្គនាយករង**

**សេក តក្កី**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានកៅស៊ូ
នាយកដ្ឋានរដ្ឋបាល និងនីតិកម្ម

## ស្ថានភាពផលិតកម្មកៅស៊ូប្រចាំខែកុម្ភៈ ឆ្នាំ២០១៩

តារាងទី១

| លរ | ចម្ការកៅស៊ូ | ផ្ទៃដី(ហិកតា) ចៀរជ័រ | ផ្ទៃដី(ហិកតា) ថែទាំ | ផ្ទៃដី(ហិកតា) សរុប | ឆ្នាំ២០១៨ ផលិតផល(តោន) ខែនេះ | ឆ្នាំ២០១៨ ផលិតផល(តោន) ដល់ខែនេះ | ឆ្នាំ២០១៨ បញ្ចេញលក់(តោន) ខែនេះ | ឆ្នាំ២០១៨ បញ្ចេញលក់(តោន) ដល់ខែនេះ | សន្និធិដើមឆ្នាំ | ឆ្នាំ២០១៩ ផលិតផល(តោន) ខែនេះ | ឆ្នាំ២០១៩ ផលិតផល(តោន) ដល់ខែនេះ | ឆ្នាំ២០១៩ បញ្ចេញលក់(តោន) ខែនេះ | ឆ្នាំ២០១៩ បញ្ចេញលក់(តោន) ដល់ខែនេះ | ប្រៀបធៀប ខែមុន ផ្ទៃដីសរុប ហិកតា | ខែមុន ផ្ទៃដីសរុប % | ខែមុន ផលិតផល តោន | ខែមុន ផលិតផល % | ខែមុន បញ្ចេញលក់ តោន | ខែមុន បញ្ចេញលក់ % | រយៈពេលដូចគ្នាឆ្នាំមុន ផលិតផល ខែនេះ តោន | ផលិតផល ខែនេះ % | ផលិតផល ដល់ខែនេះ តោន | ផលិតផល ដល់ខែនេះ % | បញ្ចេញលក់ ខែនេះ តោន | បញ្ចេញលក់ ខែនេះ % | បញ្ចេញលក់ ដល់ខែនេះ តោន | បញ្ចេញលក់ ដល់ខែនេះ % | សន្និធិ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| I. កៅស៊ូកសិឧស្សាហកម្ម | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ក | ចម្ការកៅស៊ូកសិឧស្សាហកម្ម | | | | | | | | | | | | | | | | | | | | | | | | | | | |
| 1 | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | 670 | 132 | 801 | 16 | 76 | 50 | 100 | 13 | 25 | 82 | - | - | 0 | 0 | -32 | -56 | 0 | 0 | 9 | 61 | 6 | 8 | -50 | 0 | -100 | 0 | 95 |
| 2 | ក្រុមហ៊ុនសុគន្ធីកា អ៊ីនវេសមេន គ្រុប | 12.201 | 2.870 | 15.070 | 444 | 2.135 | 851 | 1.826 | 1.286 | 706 | 2.297 | 1.219 | 3.147 | 0 | 0 | -885 | -56 | -708 | -37 | 261 | 59 | 162 | 8 | 368 | 43 | 1.321 | 72 | 436 |
| 3 | ក្រុមហ៊ុនចម្ការកៅស៊ូតាប៉ាវ | 1.120 | 914 | 2.034 | 84 | 276 | 84 | 294 | 63 | 96 | 276 | 210 | 336 | 0 | 0 | -84 | -47 | 84 | 67 | 12 | 14 | 0 | 0 | 126 | 150 | 42 | 14 | 3 |
| 4 | ក្រុមហ៊ុនចម្ការកៅស៊ូមេមត់ ខូអិលធីឌី | 5.631 | 2.809 | 8.440 | 194 | 567 | 240 | 681 | 468 | 237 | 715 | 396 | 878 | 0 | 0 | -241 | -50 | -85 | -18 | 43 | 22 | 148 | 26 | 156 | 65 | 197 | 29 | 305 |
| 5 | ក្រុមហ៊ុនស៊ីហ្វ វ៉ាប់ប៊េ លីមីធីត(រតនគិរី) | 79 | 2.646 | 2.724 | 8 | 21 | 183 | 267 | 253 | - | 601 | - | - | 0 | 0 | -601 | 0 | 0 | 0 | -8 | 0 | 580 | 2807 | -183 | 0 | -267 | 0 | 305 |
| 6 | ក្រុមហ៊ុនស៊ីហ្វ សែសស លីមីធីត(ស្នួល) | 3.859 | 548 | 4.406 | | 370 | 80 | 1.030 | 1.678 | - | 561 | 168 | 714 | 0 | 0 | -561 | 0 | -378 | -69 | 0 | 0 | 191 | 52 | 88 | 110 | -316 | -31 | 854 |
| 7 | ក្រុមហ៊ុនឡុងស្រេងអ៊ីនធើណេស៊ិនណល | 3.343 | 843 | 4.187 | 102 | 642 | 210 | 710 | 958 | - | 406 | 210 | 210 | 0 | 0 | -406 | 0 | 210 | 100 | -102 | 0 | -236 | -37 | 0 | 0 | -500 | -70 | 1.525 |
| 8 | ក្រុមហ៊ុនអានម៉ានី គ្រុប(ចម្ការឈ្លួង) | 3.848 | 1.415 | 5.263 | 71 | 219 | | 200 | 356 | 54 | 191 | | 250 | 0 | 0 | -63 | -49 | -250 | 0 | -7 | -9 | -28 | -13 | 0 | 0 | 50 | 25 | 1.164 |
| 9 | ក្រុមហ៊ុនអានម៉ានី គ្រុប(ពាមជាំង+មោសហែក) | 1.901 | 1.265 | 3.166 | 22 | 77 | | 100 | 247 | 23 | 107 | | 100 | 0 | 0 | -62 | -73 | -100 | 0 | 1 | 4 | 30 | 39 | 0 | 0 | 0 | 0 | 307 |
| 10 | ក្រុមហ៊ុនក្រែក(ខេមបូឌា) ខូអិលធីឌី | 4.359 | 439 | 4.798 | 318 | 836 | 300 | 993 | 932 | 478 | 1.177 | 840 | 1.260 | 0 | 0 | -222 | -32 | 420 | 100 | 160 | 50 | 341 | 41 | 540 | 180 | 267 | 27 | 254 |
| | សរុប ក | 37.010 | 13.880 | 50.890 | 1.259 | 5.218 | 1.999 | 6.201 | 6.274 | 1.618 | 6.412 | 3.044 | 6.895 | 0 | 0 | -3.156 | -66 | -807 | -21 | 369 | 29 | 1.194 | 23 | 1.045 | 52 | 694 | 11 | 849 |
| ខ | ចម្ការកៅស៊ូសម្បទានដីសេដ្ឋកិច្ច | 44.922 | 179.645 | 224.567 | 2.121 | 6.266 | 2.028 | 5.993 | 2.751 | 4.200 | 12.400 | 4.000 | 11.800 | 0 | 0 | -4.000 | -49 | -3.800 | -49 | 2079 | 98 | 6.134 | 98 | 1.972 | 97 | 5.807 | 97 | 5.792 |
| | សរុបI=ក+ខ | 81.932 | 193.525 | 275.457 | 3.380 | 11.484 | 4.027 | 12.194 | 9.025 | 5.838 | 18.812 | 7.044 | 18.695 | 0 | 0 | -7.156 | -55 | -4.607 | -40 | 2448 | 72 | 7.328 | 64 | 3.017 | 75 | 6.501 | 53 | 3.351 |
| | II. កៅស៊ូគ្រួសារ | 119.837 | 41.266 | 161.103 | 5.800 | 16.600 | 5.800 | 16.500 | 5.715 | 6.100 | 18.100 | 6.000 | 17.800 | 0 | 0 | -5.900 | -49 | -5.800 | -49 | 300 | 5 | 1.500 | 9 | 200 | 3 | 1.300 | 8 | 9.143 |
| | សរុបរួមI+II | 201.769 | 234.791 | 436.560 | 9.180 | 28.084 | 9.827 | 28.694 | 14.740 | 11.938 | 36.912 | 13.044 | 36.495 | 0 | 0 | -13.056 | -52 | -10.407 | -44 | 2748 | 30 | 8.828 | 31 | 3.217 | 33 | 7.801 | 27 | 6.015 |
| | | | | | | | | | | | | | | | | | | | | | | | | | | | | 15.158 |

បញ្ជាក់៖

(១) ផ្ទៃដីសរុបមានចំនួន ៤៣៦ ៥៦០ ហាត ( ផ្ទៃដីចៀរជ័រ ២០១ ៧៦៩ ហាត ថែទាំ ២៣៤ ៧៩១ ហាត) ពុំមានការប្រែប្រួលទេធៀបនឹងខែមុន។

(២) ផលិតផលសរុបចំនួន ១១ ៩២៨ តោន បានថយចុះចំនួន ១៣ ០៥៦ តោន ( ៥២%) ធៀបខែមុន និងបានកើនឡើងចំនួន២ ៧៤៨ តោន (៣០%) ធៀបនិងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៨។

(៣) រហូតមកដល់ខែកុម្ភៈ ឆ្នាំ២០១៩ ផលិតផលសរុប ៣៦ ៩១២ តោន បានកើន ៨ ៨២៨ តោន ( ៣១%)ធៀបនិងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៨។

(៤) ការបញ្ចេញលក់សរុប ១៣ ០៤៤ តោន បានថយចុះចំនួន ១០ ៤០៧តោន (៤៤%) ធៀបខែមុន នឹងបានកើនឡើងចំនួន ៣ ២១៧ តោន (៣៣%) ធៀបនិងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៨។

(៥) រហូតមកដល់ខែកុម្ភៈ ឆ្នាំ២០១៩ ការបញ្ចេញលក់សរុប ៣៦ ៤៩៥ តោន បានកើនឡើងចំនួន៧ ៨០១ តោន (២៧%) ធៀបនិងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៨។

(៦)សន្និធិចុងគ្រាមានចំនួន១៥ ១៥៨ តោន

បានឃើញ និងឯកភាព
ជ.ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា
អគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ
អគ្គនាយករង
សេក គង្គី

បានពិនិត្យត្រឹមត្រូវ
ប្រធាននាយកដ្ឋានរដ្ឋបាល និងនីតិកម្ម
ឃួន_ផល្លា

ថ្ងៃទី ៥ ១៣កើត ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២
រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ២០១៩
អ្នកធ្វើតារាង
ឡឹង ស្រីផង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានកៅស៊ូ
នាយកដ្ឋានទីផ្សារនិងសហប្រតិបត្តិការអន្តរជាតិ

## តារាងស្ថានភាពធុរកិច្ចផលិតផលជ័រកៅស៊ូស្ងួតប្រចាំខែកុម្ភៈ ឆ្នាំ២០១៩

តារាងទី២

| ល.រ | ចម្ការកៅស៊ូ | កុម្ភៈ ២០១៨ | | | | | | កុម្ភៈ ២០១៩ | | | | | | ធៀបខែមុន | | | | ធៀបរយៈពេលដូចគ្នាទៅឆ្នាំមុន | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | បរិមាណ(តោន) | | ទឹកប្រាក់($) | | តម្លៃមធ្យម($/តោន) | | បរិមាណ(តោន) | | ទឹកប្រាក់($) | | តម្លៃមធ្យម($/តោន) | | បរិមាណ | | តម្លៃមធ្យម | | បរិមាណ | | | | តម្លៃមធ្យម | | | |
| | | | | | | | | | | | | | | ខែនេះ | | ខែនេះ | | ខែនេះ | | ដល់ខែនេះ | | ខែនេះ | | ដល់ខែនេះ | |
| | | ខែនេះ | ដល់ខែនេះ | ខែនេះ | ដល់ខែនេះ | ខែនេះ | ដល់ខែនេះ | ខែនេះ | ដល់ខែនេះ | ខែនេះ | ដល់ខែនេះ | ខែនេះ | ដល់ខែនេះ | តោន | % | $/តោន | % | តោន | % | តោន | % | $/តោន | % | $/តោន | % |
| | I. កៅស៊ូកសិ-ឧស្សាហកម្ម | | | | | | | | | | | | | | | | | | | | | | | | |
| ក | ចម្ការកៅស៊ូកសិ-ឧស្សាហកម្ម | | | | | | | | | | | | | | | | | | | | | | | | |
| 1 | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | 50 | 100 | 64.000 | 126.500 | 1.280 | 1.265 | | 0 | | 0 | 0 | 0 | 0 | 0,00 | 0 | 0,00 | -50 | 0 | -100 | 0 | 0 | 0 | 0 | 0 |
| 2 | ក្រុមហ៊ុនសុភក្តិនីកា អ៊ិនវេសមេន គ្រុប | 851 | 1.826 | 1.318.896 | 2.792.614 | 1.549 | 1.530 | 1.219 | 3.147 | 1.600.258 | 4.004.329 | 1.312 | 1.273 | -708 | -36,73 | 65 | 5,20 | 368 | 43 | 1.321 | 72 | -237 | -15 | -257 | -17 |
| 3 | ក្រុមហ៊ុនចម្ការកៅស៊ូតាប៉ាវ | 84 | 294 | 125.370 | 424.410 | 1.493 | 1.444 | 210 | 336 | 268.170 | 432.600 | 1.277 | 1.288 | 84 | 66,67 | -28 | -2,15 | 126 | 150 | 42 | 14 | -216 | -14 | -156 | -11 |
| 4 | ក្រុមហ៊ុនចម្ការកៅស៊ូមេមត់ ខូអិលធីឌី | 240 | 681 | 374.088 | 1.034.008 | 1.559 | 1.519 | 396 | 878 | 539.002 | 1.143.968 | 1.359 | 1.303 | -85 | -17,62 | 102 | 8,15 | 156 | 65 | 197 | 29 | -199 | -13 | -216 | -14 |
| 5 | ក្រុមហ៊ុនស៊ីហ្វូ រ៉ាប់ប៊ើ លីមីតធីត(រតនគិរី) | 183 | 267 | 238.897 | 343.477 | 1.303 | 1.285 | | 0 | | 0 | 0 | 0 | 0 | 0,00 | 0 | 0,00 | -183 | 0 | -267 | 0 | 0 | 0 | 0 | 0 |
| 6 | ក្រុមហ៊ុនស៊ីហ្វូ វីសេសស៍ លីមីធីត(ស្នួល) | 80 | 1.030 | 116.000 | 1.435.500 | 1.450 | 1.394 | 168 | 714 | 203.280 | 843.780 | 1.210 | 1.182 | -378 | -69,23 | 37 | 3,15 | 88 | 110 | -316 | -31 | -240 | -17 | -212 | -15 |
| 7 | ក្រុមហ៊ុនឡុងស្រេងអ៊ីនធើណេស៊ិនណល | 210 | 710 | 319.200 | 1.047.000 | 1.520 | 1.475 | 210 | 210 | 272.580 | 272.580 | 1.298 | 1.298 | 210 | 100,00 | 1.298 | 100,00 | 0 | 0 | -500 | -70 | -222 | -15 | -177 | -12 |
| 8 | ក្រុមហ៊ុនអានម៉ាឌី គ្រុប(ចម្ការអណ្តូង) | 0 | 200 | 0 | 274.000 | 0 | 1.370 | | 250 | | 276.300 | 0 | 1.105 | -250 | 0,00 | -1.105 | 0,00 | 0 | 0 | 50 | 25 | 0 | 0 | -265 | -19 |
| 9 | ក្រុមហ៊ុនអានម៉ាឌី គ្រុប(ពាមជាំង) | 0 | 100 | 0 | 134.000 | 0 | 1.340 | | 100 | | 109.500 | 0 | 1.095 | -100 | 0,00 | -1.095 | 0,00 | 0 | 0 | 0 | 0 | 0 | 0 | -245 | -18 |
| 10 | ក្រុមហ៊ុនក្រែក(ខេមបូឌា) ខូអិលធីឌី | 300 | 993 | 444.000 | 1.425.750 | 1.480 | 1.436 | 840 | 1.260 | 1.072.050 | 1.594.530 | 1.276 | 1.266 | 420 | 100,00 | 32 | 2,59 | 540 | 180 | 267 | 27 | -204 | -14 | -170 | -12 |
| | **សរុប ក** | **1.999** | **6.201** | **3.000.451** | **9.037.259** | **1.501** | **1.457** | **3.044** | **6.895** | **3.955.339** | **8.677.587** | **1.299** | **1.259** | **-807** | **-20,95** | **73** | **5,96** | **1.045** | **52** | **694** | **11** | **-202** | **-13** | **-199** | **-14** |
| ខ | ចម្ការកៅស៊ូសម្បទានដីសេដ្ឋកិច្ច | 2.028 | 5.993 | 3.044.342 | 8.740.392 | 1.501 | 1.458 | 4.000 | 11.800 | 5.197.692 | 14.763.353 | 1.299 | 1.251 | -3.800 | -48,72 | 73 | 5,96 | 1.972 | 97 | 5.807 | 97 | -202 | -13 | -207 | -14 |
| | សរុបI=ក+ខ | 4.027 | 12.194 | 6.044.793 | 17.777.651 | 1.501 | 1.458 | 7.044 | 18.695 | 9.153.031 | 23.440.940 | 1.299 | 1.254 | -4.607 | -39,54 | 73 | 5,96 | 3.017 | 75 | 6.501 | 53 | -202 | -13 | -204 | -14 |
| | II. កៅស៊ូគ្រួសារ | 5.800 | 16.500 | 8.706.697 | 24.078.132 | 1.501 | 1.459 | 6.000 | 17.800 | 7.796.537 | 22.267.666 | 1.299 | 1.251 | -5.800 | -49,15 | 73 | 5,96 | 200 | 3 | 1.300 | 8 | -202 | -13 | -208 | -14 |
| | **សរុបI+II** | **9.827** | **28.694** | **14.751.490** | **41.855.782** | **1.501** | **1.459** | **13.044** | **36.495** | **16.949.569** | **45.708.606** | **1.299** | **1.252** | **-10.407** | **-44,38** | **73** | **5,96** | **3.217** | **33** | **7.801** | **27** | **-202** | **-13** | **-206** | **-14** |

**បញ្ជាក់៖**

១. ក្នុងខែកុម្ភៈ ឆ្នាំ២០១៩ បរិមាណបញ្ចេញលក់សរុបមានចំនួន១៣ ០៤៤តោន បានថយចុះចំនួន១០ ៤០៧តោន(=-៤៤,៣៨%)បើធៀបនឹងខែមុន និងបានកើនឡើងចំនួន៣ ២១៧តោន(=៣៣%)បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៨។

២. តម្លៃលក់មធ្យមក្នុងខែកុម្ភៈ ឆ្នាំ២០១៩ គឺ១ ២៩៩ដុល្លារ/តោន បានកើនឡើង ៧៣ដុល្លារ/តោន(=+៥,៩៦%)ធៀបនឹងខែមុន ប៉ុន្តែបានថយចុះ ២០២ដុល្លារ/តោន (=-១៣%)បើធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៨។

៣. រហូតមកដល់ខែកុម្ភៈ ឆ្នាំ២០១៩ បរិមាណបញ្ចេញលក់សរុបមានចំនួន៣៦ ៤៩៥តោន បានកើនឡើង៧ ៨០១តោន (=+២៧%)ធៀបរយៈពេលដូចគ្នាឆ្នាំ២០១៨។

៤. រហូតដល់ខែកុម្ភៈ ឆ្នាំ២០១៩ តម្លៃលក់មធ្យមគឺ១ ២៥២ដុល្លារ/តោន បានថយចុះ ២០៦ដុល្លារ/តោន (=-១៤%)ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០១៨។

ថ្ងៃ ចន្ទ ១៣កើត ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ២០១៩
អ្នកធ្វើតារាង

បានពិនិត្យត្រឹមត្រូវ
ប្រធាននាយកដ្ឋានទីផ្សារនិងសហប្រតិបត្តិការអន្តរជាតិ

ហ៊ិន-សាផន

បានឃើញ និងឯកភាព
ជ.ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា
អគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ
អគ្គនាយករង

ឃុន កក្កដា